ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តកំពង់ធំ

## តាងនាមប្រជារាស្ត្រខ្មែរ

-សាលក្រមព្រហ្មទណ្ឌលេខ : ៥៨ "ង"

ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ : ២៦៨

ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៩

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

-ថ្ងៃបើកសវនាការជំនុំជម្រះនិង ថ្ងៃប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី២៧-ធ្នូ-២០១៩ ។

<u>សមាសភាពចូលរួមសវនាការ មានដូចខាងក្រោម</u> :

លោក [redacted] ជាចៅក្រមជំនុំជម្រះ

លោក [redacted] ជាព្រះរាជអាជ្ញារង

កញ្ញា [redacted] ជាក្រឡាបញ្ជីសវនាការ

សាលាដំបូង ខេត្តកំពង់ធំ បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ : ២៦៨ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៩ ដែលជនជាប់ចោទមានសាវតាជាតិ ដូចខាងក្រោមៈ

១-ឈ្មោះ [redacted] ម៉េង ហៅ សុម៉េង ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ធ្វើស្រែ ។

-ទីកន្លែងកំណើត និង ទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពង់ធំ ។

-ប្តីឈ្មោះ [redacted] ភួត មានកូន០២នាក់ ។

-ឪពុកឈ្មោះ [redacted] អ៊ិរ (រស់) ម្តាយឈ្មោះ [redacted] ហួត (ស្លាប់) ។

-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ ឃុំខ្លួនថ្ងៃទី ៣០-ឧសភា-២០១៩ ។

២–ឈ្មោះ [redacted]ហេង ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ។

–ទីកន្លែងកំណើត និង ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ធំ។

–ប្តីឈ្មោះ [redacted]សុវណ្ណ មានកូន០១នាក់ ។

–ឪពុកឈ្មោះ [redacted] ម៉ុក (ស្លាប់) ម្តាយឈ្មោះ [redacted] ទន (ស្លាប់) ។

–ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ រត់គេចខ្លួន ។

ជាប់ចោទពីបទ : **ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០១-ឧសភា-២០១៩ បទប្បញ្ញត្តិដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២៨ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៣–ឈ្មោះ [redacted] គឹម ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ។

–ទីកន្លែងកំណើត និង ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ធំ។

–ប្តីឈ្មោះ [redacted] អ៊ីត មានកូន១២នាក់ ។

–ឪពុកឈ្មោះ [redacted] សន (ស្លាប់) ម្តាយឈ្មោះ [redacted]ទន (ស្លាប់) ។

–ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ រត់គេចខ្លួន ។

៤–ឈ្មោះ [redacted] ស៊ីខួន ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ។

–ទីកន្លែងកំណើតនៅ[redacted] ។

–ទីលំនៅសព្វថ្ងៃភូមិដងផ្អៀក ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

–ប្តីឈ្មោះ [redacted] ហែម មានកូន០២នាក់ ។

–ឪពុកឈ្មោះ ជុំ ម្តាយឈ្មោះ សាន។

–ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ រត់គេចខ្លួន ។

៥–ឈ្មោះ [redacted] ប៊ុណ្ណា ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ។

–ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ធំ ។

–ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ធំ។

–ប្រពន្ធឈ្មោះ [redacted] អ៊ី (ស្លាប់) មានកូន៦នាក់ ។

–ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ រី (ស្លាប់) ។

–ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ រត់គេចខ្លួន ។

៦–ឈ្មោះ [redacted] ហ៊ួ ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ។

–ទីកន្លែងកំណើត និង ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ធំ។

**-ប្រពន្ធឈ្មោះ [redacted]ផាត មានកូន៣នាក់ ។**

**-ឪពុកឈ្មោះ [redacted] សន (ស្លាប់) ម្តាយឈ្មោះ [redacted] សួត (រស់) ។**

**-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ រត់គេចខ្លួន ។**

**៧-ឈ្មោះ [redacted]គុន ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ។**

**-ទីកន្លែងកំណើត និង ទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ធំ។**

**-ប្តីឈ្មោះ [redacted] ៣ មានកូន៣នាក់ ។**

**-ឪពុកឈ្មោះ [redacted]ប៊ី (ស្លាប់) ម្តាយឈ្មោះ [redacted]គាម (ស្លាប់) ។**

**-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ រត់គេចខ្លួន ។**

**ជាប់ចោទពីបទ : ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ កាលពីថ្ងៃទី ០១-ឧសភា-២០១៩ បទប្បញ្ញត្តិដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីណាក់** ភេទប្រុស អាយុ៣២ឆ្នាំ មុខរបរមេកាឈូសឆាយ ទីលំនៅសព្វថ្ងៃភូមិដំណាក់ល្អិត ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ [redacted] ចាន់ដា មានកូន០២នាក់ ឪពុកឈ្មោះ [redacted] ច្រឹក (រស់) ម្តាយឈ្មោះ[redacted] អៀង (រស់) ។

## បានឃើញ

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ : ២៣៦៤ ចុះថ្ងៃទី ២៩-សីហា-២០១៩ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តកំពង់ធំ ។

-បានឃើញដីកាដំណោះស្រាយលេខ : ៤២២៣ ចុះថ្ងៃទី ០២-កញ្ញា-២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូង ខេត្តកំពង់ធំ ។

-បានឃើញភស្តុតាង និងឯកសារពាក់ពន្ធ័ក្នុងសំណុំរឿង ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

កាលពីថ្ងៃទី ០១-ឧសភា-២០១៩ វេលាម៉ោង ៩,០០នាទីព្រឹក នៅចំណុចភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ មានបទល្មើស ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស និង បទល្មើស ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទចំនួន៧នាក់ ។

ក្នុងនោះមានជនជាប់ចោទចំនួន០២នាក់ ឈ្មោះ[redacted]ម៉េង ហៅ សុម៉េង ភេទស្រី អាយុ៣៨ឆ្នាំ និង ឈ្មោះ [redacted] ហេង ភេទស្រី អាយុ៣៨ឆ្នាំ ជាអ្នកផ្ដើមគំនិត ។

ឯឈ្មោះ [redacted]តឹម ភេទស្រី អាយុ៥៩ឆ្នាំ ,ឈ្មោះ [redacted]ស៊ីនួន ភេទស្រី អាយុ៣៥ឆ្នាំ ,ឈ្មោះ[redacted] ប៊ុណ្ណា ភេទប្រុស អាយុ៦១ឆ្នាំ , ឈ្មោះ [redacted] ហួ ភេទប្រុស អាយុ៤១ និង ឈ្មោះ[redacted] គុន ភេទស្រី អាយុ៣៧ឆ្នាំ ជាអ្នកប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ។

ហេតុការណ៍នេះកើតនៅខណៈពេលជនរងគ្រោះឈ្មោះ [redacted] ស៊ីណាក់ ភេទប្រុស អាយុ៣៨ឆ្នាំ ជាមេការគ្រឿងចក្រ បានយកគ្រឿងចក្រទៅឈូសឆាយដីគម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋ LASED-II នៅចំណុចតំបន់ត្រពាំងស្វាយ ស្រាប់តែមានប្រជាជនប្រហែលចំនួន៨០ទៅ១០០នាក់ ដែលដឹកនាំដោយឈ្មោះ [redacted] ម៉េង និង ឈ្មោះ [redacted] ហេង ចំណែកឈ្មោះ [redacted] ហេង បានយកដុំថ្មគុបទៅលើឈ្មោះ [redacted] ស៊ីណាក់ បណ្ដាលអោយបែកហូរឈាម ឯឈ្មោះ[redacted]តឹម , ឈ្មោះ [redacted]ស៊ីនួន , ឈ្មោះ [redacted] ប៊ុណ្ណា , ឈ្មោះ [redacted] ហួ និងឈ្មោះ [redacted] គុន បាននាំចាប់ឈ្មោះ [redacted]ស៊ីណាក់ ទម្លាក់ពីលើត្រាក់ទ័ររួចនាំគ្នា ព្រួតវ៉ៃចំក្បាលបណ្ដាលអោយបែកហូរឈាមរយៈខាងស្ដាំប្រវែង ១សង់ទីម៉ែត្រ និង ស្នាមជាំក្រហមនៅលើដើមដោះខាងឆ្វេងប្រវែង ២សង់ទីម៉ែត្រ បន្ទាប់មកក៏សមត្ថកិច្ចចុះជួយអន្តរាគមន៍ក៏ជនជាប់ចោទទាំងបាននាំគ្នារត់គេចខ្លួនបាត់ ។

ចំណែកជនជាប់ចោទឈ្មោះ [redacted]ម៉េង ឃាត់ខ្លួននៅថ្ងៃទី ៣០-ឧសភា-២០១៩ តាមដីកាបញ្ជាអោយចូលខ្លួនរបស់តំណាងអយ្យការ និង ធ្វើការឃាត់ខ្លួនតែម្ដង ។

ចំណែកវត្ថុដែលចាប់យកមាន : ដំបងឈើមូលចំនួន០២ប្រវែង ៦៨សង់ទីម៉ែត្រ និង ប្រវែង ៦៤សង់ទីម៉ែត្រ មានគល់ធំ ចុងតូច ទាំងពីរ ។

## ចំលើយពិភាក្សាដេញដោលនាពេលសវនាការមាន :

**១-ជនជាប់ចោទឈ្មោះ [redacted] ម៉េង ហៅ សុម៉េង បានឆ្លើយបញ្ជាក់ថា :** បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយនៅថ្ងៃកើតហេតុថ្ងៃទី ០១-ឧសភា-២០១៩ វេលាម៉ោង ៩ព្រឹក នៅតំបន់ត្រពាំងស្វាយ ស្ថិតនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ គឺនៅថ្ងៃនោះខ្លួនមិនចូលរួមប្រព្រឹត្តទេ ដោយខ្លួននៅផ្ទះរបស់ខ្លួនមើលឪពុករបស់ខ្លួនឈឺ ម្យ៉ាងទៀតដោយហេតុថា ខ្លួនជាជួបលោកមេឃុំហើយលោកមេឃុំបានណែនាំខ្លួនថាបើចង់តវ៉ាចាំមកជួបដោះស្រាយគ្នានៅសាលាឃុំទៅមិនបាច់ទៅកន្លែងដីទំនាស់នោះទេ ដូច្នេះហើយទើបនៅថ្ងៃកើតហេតុនោះខ្លួនមិនបានទៅចូលរួមជាមួយពួកគេទេ តែកាលពីមុនៗកន្លងមកខ្លួនពិតជាបានធ្លាប់ចូលជាមួយពួកគេពិតមែន ។

នៅថ្ងៃទី ៣០-មេសា-២០១៩ ឈ្មោះ [redacted] តាល់ ពិតជាបានទូរស័ព្ទមកខ្លួនពិតមែន តែមិននិយាយអោយប្រមូលប្រជាពលរដ្ឋដើម្បីទៅចូលរួមតវ៉ានោះទេ គឺប្រជាពលរដ្ឋគេទៅតវ៉ាដោយខ្លួនគេ ។ ចំពោះដីសម្បទានសង្គមកិច្ចរបស់រដ្ឋគេមានគោលការណ៍ចែកអោយប្រជាពលរដ្ឋម្នាក់ៗចំនួន០២ហិកតា ។

**២-អំណាចឆ្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាក់ បានឆ្លើយបញ្ជាក់ថា :** កាលពីថ្ងៃទី ០១-ឧសភា-២០១៩ វេលាម៉ោង ៧,៣០នាទីព្រឹក ខ្លួននិងក្រុមការងារបួននាក់ទៀត បានចាប់ផ្តើមឈូសឆាយដីនៅតំបន់ត្រពាំងឈូក ស្ថិតក្នុងភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ក្នុងដីគម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋ ឡាសិត២ បានឈូសឆាយដីនៅតំបន់នោះបានចំនួន៧០០ហិកតា តាំងពីខែមករា ឆ្នាំ២០១៩មក ។

នៅថ្ងៃកើតហេតុម៉ោង៩,០០នាទីព្រឹក មានប្រជាពលរដ្ឋនៅភូមិដូង ប្រហែល៨០នាក់ បានមកដល់កន្លែងដែលពួកខ្លួនកំពុងឈូសឆាយដីមានត្រាក់ទ័រ០១គ្រឿង និង អាបុល០២គ្រឿង ប្រជាពលរដ្ឋទាំង៨០នាក់មកប្រាប់អោយពួកខ្លួនឈប់ឈូសឆាយ ហើយនៅកន្លែងហ្នឹងមានសមត្ថកិច្ចប្រហែល៦នាក់ ពួកគាត់ក៏នៅក្បែរពួកខ្លួន ប្រាប់អោយពួកខ្លួនឈប់ឈូសឆាយសិន ពេលនោះមានប្រពលរដ្ឋចំនួន៣០នាក់ ស្ទុះបំរុងមកវាយតែកុងបើកអាត្រាក់របស់ខ្លួន ហើយតែកុងអាត្រាក់នោះក៏ស្ទុះចេញពីអាត្រាក់គេចពីប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋម្នាក់និយាយថាសោរអាត្រាក់ជាប់នឹងអាត្រាក់ មានអ្នកណាចេះបើកអាត្រាក់ យកអាត្រាក់ចេញទៅ ពេលឮដូច្នេះខ្លួនស្ទុះទៅដកសោរបានក៏មានប្រជាពលរដ្ឋប្រហែល៣០នាក់នោះ មកទាញដៃ វ៉ៃចំទ្រូង វ៉ៃខ្នង បណ្តាលអោយរូបខ្លួនឈឺ ហើយរូបខ្លួនបានឃើញម្នាក់ឈ្មោះ [redacted] ហេង ភេទស្រី បានទាញដុំដីគុបរូបខ្លួនចំក្បាលបណ្តាលអោយបែកចេញឈាម ចំណែកបក្ខពួកផ្សេងទៀតដែលវ៉ៃរូបខ្លួនអត់ស្គាល់ទេ ឯក្រុមការងាររបស់ពួកខ្លួនចំនួន០៤នាកទៀតអត់ត្រូវអីទេ បានរត់ទៅក្បែរសមត្ថកិច្ច ហើយសមត្ថកិច្ចបានមកឃាត់ប្រជាពលរដ្ឋកុំអោយវាយរូបខ្លួនបន្តទៀត ។

ខ្លួនសំណូមទាមទារសំណងជម្ងឺចិត្តចំនួន ៥,០០០ដុល្លារអាមេរិក (ប្រាំពាន់ដុល្លារអាមេរិក) ។

**៣-អំណាចឆ្លើយសាក្សីបំភ្លឺមាន :**

**ក**-សាក្សីបំភ្លឺឈ្មោះ [redacted] តាល់ ភេទប្រុស អាយុ៣៨ឆ្នាំ បានឆ្លើយបំភ្លឺថា : នៅក្នុងកំឡុងខែធ្នូ ឆ្នាំ ២០១៨ មានឈ្មោះ [redacted] ហ៊ីម ភេទប្រុស នៅភ្នំពេញ និងឈ្មោះ [redacted] ម៉ៅ ភេទប្រុស នៅស្រុកប្រាសាទបល្ល័ង្គ បានធ្វើការញុះញង់ប្រជាពលរដ្ឋអោយធ្វើការតវ៉ាប្រឆាំង និង គម្រោងដីសម្បទានសង្គមកិច្ចរបស់រដ្ឋ ចំណែកខ្លួនក៏បានចូលរួមសកម្មភាពក្នុងការតវ៉ានេះដែរ ហើយការតវ៉ានេះបានអូសបន្លាយពេលវេលារហូតមកដល់ខែមេសា ឆ្នាំ២០១៩ ដោយពិនិត្យឃើញថាការតវ៉ានេះជាអំពើខុសច្បាប់ និង មិនទទួលបានលទ្ធផលទើបខ្លួនសម្រេចចិត្តដកខ្លួនចេញ នៅសល់តែឈ្មោះ ម៉ុក ហេង និង ឈ្មោះ អ៊ាវ ម៉េង ជាអ្នកដឹកនាំបំផុសបំផុលអោយប្រជាពលរដ្ឋមានការតវ៉ាក្រោមបញ្ជាពីឈ្មោះ [illegible] និង ឈ្មោះ [redacted] រដ្ឋា ប្រធានអង្គការអាដហុកប្រចាំនៅខេត្តកំពង់ធំ ។

នៅថ្ងៃទី ៣០-មេសា-២០១៩ វេលាម៉ោង៥ល្ងាច ឈ្មោះ [redacted]ហេង និងឈ្មោះ [redacted] ម៉េង បានទូរស័ព្ទមកខ្លួនថាស្អែកនេះយើងនាំប្រជាពលរដ្ឋទៅកន្លែងឈូសឆាយហើយទៅស្ទើជើងទៅឃាត់គ្រឿងចក្រនោះអោយបានហើយដាក់ទឹកគ្រប់គ្នា ។

នៅថ្ងៃទី ០១-ឧសភា-២០១៩ នៅពេលព្រឹកប្រជាពលរដ្ឋបាននាំគ្នាទៅតំបន់ឈូសឆាយនៅត្រពាំងស្វាយ ខ្លះមានពូថៅ ខ្លះមានកាំបិតផ្គាក់គ្រប់ដៃ ពេលទៅដល់ប្រជាពលរដ្ឋបាននាំហ៊ុំព័ទ្ធគ្រឿងចក្រ ហើយស្រែកគំរាមតែកុងគ្រឿងចក្រថាកុំរត់ទៅណាអោយសោះ អ្នែងហៅមេឃុំមកជួបយើងពុំដូច្នេះដុតអាត្រាក់ទ័រចោល ខ្លះដេរប្រមាថ និង ចាប់តែកុងគ្រឿងចក្រវាយបណ្តាលអោយមានរបួស ។ ចំណែកខ្លួនគឺនិយាយតែពាក្យសំដីទេ គ្មានប្រព្រឹត្តដៃដល់ឡើយ ហើយរាល់ការប្រព្រឹត្តសកម្មភាពល្មើសច្បាប់វាយតប់អ្នកបើកគ្រឿងចក្រអោយមានរបួសឮគេថាឈ្មោះ [redacted] ហេង នៅពេលនោះខ្លួនអត់ឃើញដែរព្រោះមនុស្សច្រើន ។

**ខ**-សាក្សីបំភ្លឺឈ្មោះ [redacted] រ៉ា ភេទប្រុស អាយុ៣០ឆ្នាំ បានឆ្លើយបំភ្លឺថា : នៅថ្ងៃទី ០១-ឧសភា-២០១៩ វេលាម៉ោង៩,០០នាទី ព្រឹក ខ្លួនកំពុងបើកត្រាក់ទ័រឈូសឆាយដីសម្បទានសង្គមកិច្ចរបស់រដ្ឋស្រាប់តែមានប្រពលរដ្ឋមានគ្នាប្រហែល៨០ ទៅ១០០នាក់ ដោយមានទាំងប្រុស ទាំងស្រី មានកាន់ដំបងកាំបិត ពូថៅ មកដល់បញ្ជាអោយខ្លួនឈប់ត្រាក់ទ័រ ហើយហ៊ុំព័ទ្ធត្រាក់ទ័រ ដោយមានបុរសម្នាក់ឡើងទៅទាញដៃខ្លួនទំលាក់ពីលើត្រាក់ទ័រ តែមិនមានវ៉ៃតប់ទេ ឃើញដូច្នេះមេការឈ្មោះ [redacted] ស៊ីណាក់ បានឡើងត្រាក់ទ័រទៅដកកូនសោរ ដើម្បីយកទុកព្រោះខ្លាចពួកគេបើត្រាក់ទ័រយកទៅ ភ្លាមនោះប្រជាពលរដ្ឋ ដែលមកតវ៉ាព័ទ្ធត្រាក់ទ័របានដុំដីគុបទៅលើមេកា និង ខ្លះទៀតគុបនឹងឈើ ហើយទាញមេការទំលាក់ពីលើត្រាក់ទ័រ ហើយយកឈើវាយបន្ថែមទៀត ពេលនោះមេការបានរត់គេចពីក្រុមរង្វង់មនុស្សដែលមកតវ៉ា ។ ចំណែកខ្លួននៅឈរកន្លែងត្រាក់ទ័រដដែល ដោយប្រជាពលរដ្ឋមកតវ៉ានិយាយថារងចាំអោយមេភូមិ មេឃុំមកដោះស្រាយសិន ក្រោយមកពួកគាត់បាននាំគ្នាប្រមូលឈើគរដាក់កងត្រាក់ទ័រ ហើយគំរាមដុតត្រាក់ទ័រចោល ភ្លាមនោះសមត្ថកិច្ចមកដល់និយាយចរចារជាមួយពួកគាត់រហូតដល់ម៉ោង៥ល្ងាច ទើបប្រពលរដ្ឋនាំគ្រឡប់ទៅផ្ទះវិញ ។

**គ**-សាក្សីបំភ្លឺឈ្មោះ [redacted] វ៉ាន់នី ភេទប្រុស អាយុ៣២ឆ្នាំ បានឆ្លើយបំភ្លឺថា : នៅថ្ងៃទី ០១-ឧសភា-២០១៩ ខ្លួនត្រូវបានប្រធានអង្គភាពបញ្ជាអោយមកការពារនៅតំបន់ស្ពានគុយស្ថិតក្នុងគំរោងដីសម្បទានសង្គមកិច្ចឡាសិត២ ដែលជាកន្លែងអាប៊ុល និង ត្រាក់ទ័រឈូសឆាយដី ពេលខ្លួនមកដល់នៅម៉ោង៧,៣០នាទី បានឃើញគ្រឿងចក្រកំពុងឈូសឆាយធម្មតាពុំមានសកម្មភាពអ្វីកើតឡើងទេ ។

លុះដល់ម៉ោង៩,០០នាទីព្រឹក ខ្លួនបានប្រជាពលរដ្ឋចំនួន២២នាក់ ប្រុស៨នាក់ ដើរចេញពីព្រៃ បន្ទាប់មកខ្លួនប្រាប់ទៅមេគ្រឿងចក្រថាផ្អាកឈូសសិនទៅមានប្រជាពលរដ្ឋមកតវ៉ា ហើយ ពេលនោះ

គ្រឿងចក្របានឈប់ឈូសសិន ហើយបត់ត្រឡប់ក្រោយបំរុងមកកន្លែងស្នាក់ការគ្រឿងចក្រវិញ ពេលមកបានចម្ងាយប្រហែល១៥ម៉ែត្រ ស្រាប់តែប្រជាពលរដ្ឋនាំគ្នាមកស្ទាក់ និង ឃាត់គ្រឿងចក្រអោយឈប់ ដោយប្រជាពលរដ្ឋម្នាក់ៗប្រដាប់ដោយអាវុធរួមមាន ពូថៅ កាំបិតផ្គាក់ ដំបង ចបជីក និង ចប់កាប់ មកហ៊ុំព័ទ្ធគ្រឿងចក្រ ពេលនោះខ្លួនឃើញឈ្មោះ [redacted]គាល់ ភេទប្រុស និង បក្ខពួកជាច្រើននាក់ទៀតឡើងទាញតែកុងត្រាក់ទ័រទំលាក់មកដី ។ បន្ទាប់មកខ្លួនឃើញមេការឈ្មោះ [redacted]ស៊ីណាក់ ឡើងទៅលើត្រាក់ទ័រដើម្បីដកសោរយកមកទុក ភ្លាមនោះខ្លួនឃើញប្រជាពលរដ្ឋមួយចំនួនខ្លះគុបដុំដី និងខ្លះទៀតគុបនិងដំបងទៅលើមេការដែលកំពុងនៅលើត្រាក់ទ័រ ហើយខ្លះទៀតចាប់ទាញដៃជើងទំលាក់មកក្រោម ពេលមកដល់ក្រោមមានអ្នកវ៉ៃនិងដំបងថែមទៀតបណ្តាលអោយមានរបួស ។ ក្រោយមកដោយមានការសម្របសម្រួលពីស្ថាប័នមានសមត្ថកិច្ចអោយបញ្ឈប់សកម្មភាពទៅរងចាំការដោះស្រាយវិញ ។

## ៤-អំណានរបាយការណ៍ផ្សេងៗ

**ក**-របាយការណ៍របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំលេខ : ០៧៦ ចុះថ្ងៃទី ២៤-ឧសភា-២០១៩ ការសន្និដ្ឋាន : ឆ្លងតាមការស្រាវជ្រាវ អង្កេតដោយផ្ទាល់ និង ការប្រមែប្រមូលភស្តុតាងដែលបានបន្សល់ទុកនៅកន្លែងកើតហេតុ និង ការបំភ្លឺរបស់សាក្សី យើងសន្និដ្ឋានថា បទល្មើសហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ទៅលើជនរងគ្រោះឈ្មោះ [redacted] ស៊ីណាក់ ភេទប្រុស កាលពីថ្ងៃទី ០១-ឧសភា-២០១៩ ចំណុចតំបន់ត្រពាំងស្វាយ ភូមិសាស្ត្រភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំក្នុងដីគម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋ គឺប្រព្រឹត្តឡើងដោយឈ្មោះ [redacted] ហេង ភេទស្រី ,ឈ្មោះ [redacted] ម៉េង ភេទស្រី ,ឈ្មោះ [redacted] គឹម ភេទស្រី ,ឈ្មោះ [redacted]ស៊ីទួន ភេទស្រី ,ឈ្មោះ [redacted] ប៊ុណ្ណា ភេទប្រុស និង បក្ខពួកមួយចំនួនទៀត ។

**ខ**-កំណត់ហេតុទទួលវត្ថុចាប់យករបស់តំណាងអយ្យការលេខ : ៦៦ ថ្ងៃទី ២៧-ឧសភា-២០១៩ មាន : ដំបងឈើមូលចំនួន០២ប្រវែង ៦៨សង់ទីម៉ែត្រ និង ប្រវែង ៦៤សង់ទីម៉ែត្រ មានគល់ធំចុងតូច ទាំងពីរ ។

**គ**-កំណត់ហេតុពិនិត្យវិភាគស្លាកស្នាមរបស់មន្ត្រីនគរបាលយុត្តិធម៌ចុះថ្ងៃទី ០២-ឧសភា-២០១៩ បានដំណើរការពិនិត្យស្លាកស្នាមលើឈ្មោះ [redacted]ស៊ុណាក់ អំពីស្ថានភាពមុខរបួស ស្នាមរបួសបែកក្បាលផ្នែកខាងលើខាងស្តាំ ប្រវែង១សង់ទីម៉ែត្រ ចំនួន០១កន្លែង មានហើមហូរ ស្នាមជាំក្រហមនៅលើដើមដោះ ផ្នែកខាងឆ្វេងប្រវែង៤សង់ទីម៉ែត្រ ។

**សេចក្តីកត់សម្គាល់ខ្លីៗ និង សំណូមពរចុងក្រោយរបស់ជនជាប់ចោទ**

ខ្លួនសុំធ្វើសេចក្តីកត់សម្គាល់ខ្លីៗបន្ថែមថា នៅថ្ងៃកើតហេតុគឺខ្លួនពិតជាមិនបានចូលរួមប្រព្រឹត្តជាមួយពលរដ្ឋទាំងនោះទេ តែខ្លួនបានចូលរួមនូវរាល់សកម្មភាពតវ៉ាលើកៗមុន ។

ខ្លួនសំណូមពរ សុំអោយតុលាការដោះលែងខ្លួនអោយមានសេរីភាពវិញ ពេលដែលខ្លួនបាននៅក្រៅឃុំមិនចូលទៅពាក់ព័ន្ធនឹងដីកម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋទៀតឡើយ ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា :**

ក្រោយបានបញ្ចប់ការសួរដេញដោលនាពេលសវនាការរួមមកឃើញថាអង្គហេតុមានការប្រទាក់ក្រឡាគ្នា ដោយមានការលើកគ្នាមកតវ៉ាលើដីកម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋ ។

នៅថ្ងៃកើតហេតុគឺក្រុមតវ៉ាបានអូសតែកុងត្រាក់ទ័រ និង មេការគ្រប់គ្រងត្រាក់ទ័រទម្លាក់ពីលើត្រាក់ទ័រហើយព្រួតគ្នាវ៉ៃបណ្តាលអោយមានរបួសជាច្រើនកន្លែង ដូចមានក្នុកំណត់ហេតុពិនិត្យស្នាមរបួសរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

ជនជាប់ចោទឈ្មោះ [redacted] ម៉េង បានឆ្លើយបដិសេធថានៅថ្ងៃទី ០១-ឧសភា-២០១៩ ខ្លួនមិនបានចូលរួមប្រព្រឹត្តទេ តែជនជាប់ចោទរូបនេះបានឆ្លើយទទួលស្គាល់ថា នៅថ្ងៃទី ៣០-មេសា-២០១៩ គឺខ្លួនពិតជាបានទូរស័ព្ទទាក់ទងគ្នាដើម្បីរៀបចំកំលាំងតវ៉ានៅថ្ងៃបន្ទាប់ពិតមែន ។

នៅថ្ងៃទី ០១-ឧសភា-២០១៩ ក្រុមតវ៉ាគឺសុទ្ធតែជាក្រុមដែលធ្លាប់តវ៉ាពីមុនៗមក ដោយមានការផ្តួចផ្តើមនិងដឹកនាំដោយឈ្មោះ [redacted] ម៉េង និង ឈ្មោះ [redacted] ហេង ។

មានសាក្សីសំខាន់ម្នាក់ឈ្មោះ [redacted] តាន់ ដែលធ្លាប់ធ្វើក្រុមតវ៉ាជាមួយឈ្មោះ [redacted] ម៉េង និង ឈ្មោះ [redacted] ហេង តែក្រោយមកឈ្មោះ [redacted] តាន់ បានដឹងពីអំពើប្រព្រឹត្តរបស់ខ្លួនខុសច្បាប់ក៏បានដកខ្លួនចេញ ហើយរៀបរាប់នូវហេតុការណ៍យ៉ាងច្បាស់តាំងដំបូងមកដូចមានក្នុងកំណត់ហេតុយកចម្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ស្រាប់ ។

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉េង និង ចម្លើយសាក្សីបំភ្លឺ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ម៉េង និង ឈ្មោះ [redacted] ហេង ពិតជាបានប្រព្រឹត្តអំពើ ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ឯឈ្មោះ [redacted] ហេង , [redacted] គីម , [redacted] ស៊ីនួន , [redacted] ប៊ុណ្ណា , [redacted] ហួ និង ឈ្មោះ ប៊ី គុន ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនា ពិតប្រាកដមែន ។

ដូច្នេះតំណាងអយ្យការស្នើសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់របស់ជនរងគ្រោះ

ក្រោយពីបានស្តាប់អំណាចម្លើយសាក្សីបំភ្លឺ

ក្រោយពីបានស្តាប់សេចក្តីកត់សម្គាល់ខ្លី និង សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារពាក់ពន្ធ័ក្នុងសំណុំរឿង

## សាលាដំបូង ខេត្តកំពង់ធំ

## យល់ឃើញថា

១-កាលពីថ្ងៃទី ០១-ឧសភា-២០១៩ វេលាម៉ោង ៩,០០នាទីព្រឹក នៅចំណុចភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ពិតជាមានបទល្មើស ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស និង បទល្មើស ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទចំនួន៧នាក់ ។ ក្នុងនោះមានជនជាប់ចោទចំនួន០២នាក់ ឈ្មោះ [redacted] ម៉េង ហៅ សុម៉េង ភេទស្រី អាយុ៣៨ឆ្នាំ និង ឈ្មោះ [redacted] ហេង ភេទស្រី អាយុ៣៨ឆ្នាំ ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ។

ឯឈ្មោះ [redacted] តឹម ភេទស្រី អាយុ៥៩ឆ្នាំ ,ឈ្មោះ ជុំ ស៊ីនួន ភេទស្រី អាយុ៣៥ឆ្នាំ ,ឈ្មោះ [redacted] ប៊ុណ្ណា ភេទប្រុស អាយុ៦១ឆ្នាំ , ឈ្មោះ [redacted] ហួ ភេទប្រុស អាយុ៤១ និង ឈ្មោះ [redacted] គុន ភេទស្រី អាយុ៣៧ឆ្នាំ ជាអ្នកប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ម៉េង បានឆ្លើយបញ្ជាក់ថា : នៅថ្ងៃកើតហេតុថ្ងៃទី ០១-ឧសភា-២០១៩ វេលាម៉ោង ៩ព្រឹក នៅតំបន់ត្រពាំងស្វាយ ស្ថិតនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ គឺនៅថ្ងៃនោះខ្លួនមិនចូលរួមប្រព្រឹត្តទេ ដោយនៅផ្ទះរបស់ខ្លួនមើលឪពុករបស់ខ្លួនឈឺ ម្យ៉ាងទៀតដោយហេតុថា ខ្លួនជាជួបលោកមេឃុំហើយលោកមេឃុំបានណែនាំខ្លួនថាបើចង់តវ៉ាចាំមកជួបដោះស្រាយគ្នានៅសាលាឃុំទៅមិនបាច់ទៅកន្លែងដីទំនាស់នោះទេ ។

៣-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ស៊ីណាក់ បានឆ្លើយបញ្ជាក់ថា : នៅថ្ងៃកើតហេតុម៉ោង៩,០០នាទីព្រឹក មានប្រជាពលរដ្ឋនៅភូមិដូង ប្រហែល៨០នាក់ បានមកដល់ កន្លែងដែលពួកខ្លួនកំពុងឈូសឆាយដីមានត្រាក់ទ័រ០១គ្រឿង និង អាបុល០២គ្រឿង ប្រជាពលរដ្ឋទាំង៨០នាក់ មកប្រាប់អោយពួកខ្លួនឈប់ឈូសឆាយ ពេលនោះមានប្រពលរដ្ឋចំនួន៣០នាក់ ស្ទុះបំរុបមកវាយតែកុងមើកអាត្រាក់របស់ខ្លួន ហើយប្រជាពលរដ្ឋម្នាក់និយាយថាសោរអាត្រាក់ជាប់នឹងអាត្រាក់ មានអ្នកណាចេះបើកអាត្រាក់យកអាត្រាក់ ចេញទៅពេលឮដូច្នេះខ្លួនស្ទុះទៅដកសោរបានក៏មានប្រជាពលរដ្ឋប្រហែល៣០នាក់នោះ មកទាញដៃ ទើបទ្រូង ខ្នង

បណ្តាលអោយរូបខ្លួនឈឺ ហើយរូបខ្លួនបានឃើញម្នាក់ឈ្មោះ [redacted] ហេង ភេទស្រី បានទាញដុំដីគុប រូបខ្លួនចំក្បាលបណ្តាលអោយបែកចេញឈាម។

៤-អំណានចម្លើយសាក្សីបំភ្លឺឈ្មោះ [redacted] គាល់ ភេទប្រុសបានឆ្លើយបំភ្លឺថា : នៅក្នុងកំឡុងខែធ្នូ ឆ្នាំ ២០១៨ ហើយការតវ៉ានេះបានអូសបន្លាយពេលវេលារហូតមកដល់ខែមេសា ឆ្នាំ២០១៩ ដោយពិនិត្យឃើញថាការតវ៉ានេះជាអំពើខុសច្បាប់ និង មិនទទួលបានលទ្ធផលទើបខ្លួនសម្រេចចិត្តដកខ្លួនចេញនៅសល់តែឈ្មោះ [redacted] ហេង និង ឈ្មោះ [redacted] ម៉េង ជាអ្នកដឹកនាំបំផុសបំផុលអោយប្រជាពលរដ្ឋមានការតវ៉ាក្រោមបញ្ជាពីឈ្មោះ [redacted] ហ៊ីម និង ឈ្មោះ [redacted] រដ្ឋា ប្រធានអង្គការអាដហុកប្រចាំនៅខេត្តកំពង់ធំ ។ នៅថ្ងៃទី ០១-ឧសភា-២០១៩ នៅពេលព្រឹកប្រជាពលរដ្ឋបានគ្នាទៅតំបន់ឈូសឆាយនៅ ត្រពាំងស្វាយ ខ្លះមានពូថៅ ខ្លះមានកាំបិតផ្គាក់គ្រប់ដៃ ពេលទៅដល់ប្រជាពលរដ្ឋបាននាំហ៊ុំព័ទ្ធគ្រឿងចក្រ ខ្លះជេរប្រមាថ និង ចាប់តែកុងគ្រឿងចក្រវាយបណ្តាលអោយមានរបួស ។

៥-តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះ ចម្លើយសាក្សីបំភ្លឺ និង របាយការណ៍នានារបស់មន្ត្រីនគរបាលយុត្តិធម៌ឃើញថាមានលក្ខណៈស៊ីសង្វាក់គ្នាដែលបង្ហាញអោយឃើញច្បាស់ថា គឺថ្ងៃទី ៣០-មេសា-២០១៩ គឺជនជាប់ចោទឈ្មោះ [redacted] ម៉េង ពិតជាបានទូរស័ព្ទទៅឈ្មោះ [redacted] គាល់ អោយប្រមូលប្រជាពលរដ្ឋដើម្បីទៅ ចូលតវ៉ាផ្អាកត្រាក់ទ័រមិនអោយឈូសឆាយដីសម្បទានសង្គមកិច្ចរបស់រដ្ឋពិតមែន ។ លុះពេលកើតហេតុដោយប្រជាពលរដ្ឋច្រើននាក់ហើយជនជាប់ចោទឈ្មោះ [redacted] ម៉េង និង [redacted] ហេង មិនអាចគ្រប់គ្រងសភាពការណ៍បានក៏បណ្តាលអោយកើតនូវអំពើហិង្សាទៅជនរងគ្រោះដែលជាមេការគ្រប់គ្រងលើការឈូសឆាយនោះតែម្តង ។

ដូច្នេះអំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងពីរនាក់ប្រព្រឹត្តឡើងមកនេះ អាចអោយតុលាការសន្និដ្ឋានបានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉េង និង [redacted] ហេង គឺអំពើ ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ។ ឯឈ្មោះ [redacted] គីម , [redacted] ស៊ីនួន , [redacted] ប៊ុណ្ណា , [redacted] ហួ និង ឈ្មោះ [redacted] គុន គឺអំពើ ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ពិតប្រាកដមែន ។

៦-ជនជាប់ចោទឈ្មោះ [redacted] ហេង , [redacted] គីម , [redacted] ស៊ីនួន , [redacted] ប៊ុណ្ណា , [redacted] ហួ និង ឈ្មោះ [redacted] គុន ក្រោយពីបានប្រព្រឹត្តបទល្មើសគេចខ្លួនរហូតមក ដោយចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់អោយចាប់ជនជាប់ចោទទាំង៦នាក់នេះ ហើយនៅតែមិនមានលទ្ធផលដដែល ។ ដូច្នេះគប្បីតុលាការប្រកាសផ្តន្ទាទោសជនជាប់ចោទទាំង៦នាក់នេះ និង ចេញដីកាបង្គាប់អោយចាប់ខ្លួនបន្ត ដោយយោងតាមមាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ០១ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទេ តុលាការតាមសេចក្តីសម្រេចពិសេស និង ដោយមានសំអាងហេតុអាចចេញនូវក្នុងពេលសវនាការ នូវដីកាបង្គាប់អោយចាប់ខ្លួនជនជាប់ចោទអវត្តមាន ។

៧-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាក់ បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៥,០០០ដុល្លារអាមេរិក (ប្រាំពាន់ដុល្លារអាមេរិក) ការប្តឹងសុំនេះ តុលាការសម្រេចតាមការជាក់ស្តែង ។

៨-ជនជាប់ចោទឈ្មោះ [redacted] ម៉េង បានស្នើសុំអោយតុលាការបន្ធូបន្ថយទោសដល់ខ្លួនផង នៅពេលដែលខ្លួនបានចេញនៅក្រៅឃុំមិនចូលទៅពាក់ព័ន្ធក្នុងដីគម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋទៀតទេ ។

ការស្នើសុំ នេះតុលាការនឹងទទួលមកពិចារណា ដោយហេតុថា ជនជាប់ចោទបានឆ្លើយទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួនដែលបានប្រព្រឹត្តឡើងមកធ្វើអោយប៉ះពាល់ដល់ដីគម្រោងសម្បទានសង្គមកិច្ចរបស់រដ្ឋ ដោយខ្លួនមិនប្រព្រឹត្តទៀតឡើយ ។ ដូច្នេះគប្បី តុលាការផ្តល់ការព្យួរទោសដល់ជនជាប់ចោទ ដោយយោងតាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ចែងថា ការព្យួរទោសធម្មតា កាលបើទោសដែលប្រកាសនោះ តិចជាង ឬ ស្មើនឹង៥ឆ្នាំ ។

៩-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ អោយតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ ការប្តឹងសុំតុលាការនឹងទទួលមកពិចារណារ ។

១០-វត្ថុដែលចាប់យកមាន ដំបងឈើមូលចំនួន០២ប្រវែង ៦៨សង់ទីម៉ែត្រ និង ប្រវែង ៦៤សង់ទីម៉ែត្រ។ តុលាការនឹងសម្រេចតាមច្បាប់ ដោយយោងតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

១១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ :

ក-ឈ្មោះ [redacted] ម៉េង ហៅ សុម៉េង ភេទស្រី អាយុ៣៨ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ខ-ឈ្មោះ [redacted] ហេង ភេទស្រី អាយុ៣៨ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ពីបទ : ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០១-ឧសភា-២០១៩ បទប្បញ្ញត្តិដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២៨ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

គ-ឈ្មោះ [redacted] តឹម ភេទស្រី អាយុ៥៩ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ឃ-ឈ្មោះ [redacted] ស៊ុនួន ភេទស្រី អាយុ៣៥ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ង-ឈ្មោះ [redacted] ប៊ុណ្ណា ភេទប្រុស អាយុ៦១ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ច-ឈ្មោះ [redacted] ហួ ភេទប្រុស អាយុ៤១ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ឆ-ឈ្មោះ [redacted] គុន ភេទស្រី អាយុ៣៧ឆ្នាំ ដែលមានសាវតាជាតិខាងលើ

ពីបទ : ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០១-ឧសភា-២០១៩ បទប្បញ្ញត្តិដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសាលាដំបូង ខេត្តកំពង់ធំ

## វិនិច្ឆ័យសេចក្តី

**១**-ផ្តន្ទាទោសជនជាប់ចោទមានដូចខាងក្រោម :

**ក-ឈ្មោះ [redacted] ម៉េង ហៅ សុម៉េង ភេទស្រី អាយុ៣៨ឆ្នាំ** ដែលមានសាវតាជាតិខាងលើ

**ខ-ឈ្មោះ [redacted] ហេង ភេទស្រី អាយុ៣៨ឆ្នាំ** ដែលមានសាវតាជាតិខាងលើ

ដាក់ពន្ធនាគារ ម្នាក់ៗកំណត់ចំនួន ០៣ឆ្នាំ (បីឆ្នាំ) ទោសអនុវត្តពន្ធនាគារនេះ ជនជាប់ចោទម្នាក់ៗត្រូវទទួលអនុវត្តដូចខាងក្រោម :

**-ឈ្មោះ [redacted] ម៉េង ហៅ សុម៉េង** អនុវត្តទោសគិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី ៣០-ឧសភា-២០១៩ មកត្រឹមថ្ងៃប្រកាសសាលក្រម ទោសដែលនៅសល់ត្រូវព្យួរធម្មតា ។

**-ឈ្មោះ [redacted] ហេង** អនុវត្តទោសគិតពីថ្ងៃចាប់ខ្លួនបាន ។

**ជនជាប់ចោទទាំងពីរនាក់ត្រូវបានផ្តន្ទាទោសពីបទ : ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០១-ឧសភា-២០១៩ បទប្បញ្ញត្តិដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២៨ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**គ-ឈ្មោះ [redacted] គីម ភេទស្រី អាយុ៥៩ឆ្នាំ ដែលមានសាវតាជាតិខាងលើ**

**ឃ-ឈ្មោះ [redacted] ស៊ីនួន ភេទស្រី អាយុ៣៥ឆ្នាំ ដែលមានសាវតាជាតិខាងលើ**

**ង-ឈ្មោះ [redacted] ប៊ុណ្ណា ភេទប្រុស អាយុ៦១ឆ្នាំ ដែលមានសាវតាជាតិខាងលើ**

**ច-ឈ្មោះ [redacted] ហួ ភេទប្រុស អាយុ៤១ឆ្នាំ ដែលមានសាវតាជាតិខាងលើ**

**ឆ-ឈ្មោះ [redacted] គុន ភេទស្រី អាយុ៣៧ឆ្នាំ ដែលមានសាវតាជាតិខាងលើ**

ដាក់ពន្ធនាគារ ម្នាក់ៗកំណត់ចំនួន ០២ឆ្នាំ (ពីរឆ្នាំ) ដោយអនុវត្តទោសគិតពីថ្ងៃចាប់ខ្លួនបាន ។

**ជនជាប់ចោទទាំងប្រាំនាក់ត្រូវបានផ្តន្ទាទោសពីបទ : ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិក្របៅ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០១-ឧសភា-២០១៩ បទប្បញ្ញត្តិដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**២**-បង្គាប់អោយជនជាប់ចោទឈ្មោះ **[redacted] ម៉េង , [redacted] ហេង , [redacted] គីម , [redacted] ស៊ីនួន , [redacted] ប៊ុណ្ណា, [redacted] ហួ និង ឈ្មោះ [redacted] គុន** រួបរួមគ្នាសងសំណងជម្ងឺចិត្តអោយទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **[redacted] ស៊ីណាក់** ចំនួន ៤,០០០,០០០រៀល (បួនលានរៀល) សំណូមពរទាមទារលើសពីនេះ ត្រូវបដិសេធចោល ។

៣–វត្ថុចាប់យកដែលត្រូវរឹបអូសមាន ៖ ដំបងឈើមូលចំនួន០២ប្រវែង ៦៨សង់ទីម៉ែត្រ និង ប្រវែង ៦៤សង់ទីម៉ែត្រ។

៤–ចេញដីកាបង្គាប់អោយចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **ហេង , ឈ្មោះ** [redacted] **គឹម ,ឈ្មោះ** [redacted] **ស៊ីនួន, ឈ្មោះ** [redacted] **ប៊ុណ្ណា ,ឈ្មោះ** [redacted] **ហួ និង ឈ្មោះ** [redacted] **គុន** ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉េង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហេង , ឈ្មោះ [redacted] គឹម ,ឈ្មោះ [redacted] ស៊ីនួន , ឈ្មោះ [redacted] ប៊ុណ្ណា ,ឈ្មោះ [redacted] ហួ និង ឈ្មោះ [redacted] គុន និង កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាក ទុកសិទ្ធិអោយប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**

**ហត្ថលេខា និង ត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា** [redacted]

---

**បានថតចម្លងចេញត្រឹមត្រូវតាមសាលក្រមដើម**

**ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣**

**ធ្វើនៅកំពង់ធំ . ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner